# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤០៣.អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពីការបែងចែកចំណូលថវិកាចរន្តរបស់រដ្ឋ តាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃ ទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥, ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ , ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្ដីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា១ :** ឥណទានចំណូលនៃថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨ ត្រូវបានបែងចែកតាមក្រសួងនីមួយៗ តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដែលមានប្រភពចំណូល និង តាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដូចមានក្នុងតារាងជូនភ្ជាប់ជាមួយអនុក្រឹត្យនេះ ។

**មាត្រា២ :** ចំណូលទាំងអស់នេះ ត្រូវបានប្រមូលដើម្បីគុណប្រយោជន៍ ដល់ថវិកាទូទៅរបស់រដ្ឋ និង ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការបែងចែកចំណូលនៃជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**... ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# តារាងបែងចែកចំណូលចរន្ត និង ចំណូលមូលធន
# សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨

ឯកតា:លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | ០១. ព្រះបរមរាជវាំង | 1.157,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 1.157,0 |
| | ០៥. គណៈរដ្ឋមន្ត្រី | 177.359,3 |
| | ផ្នែក ១_ទីស្តីការគណៈរដ្ឋមន្ត្រីផ្ទាល់ | 124.843,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 2.420,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 122.423,0 |
| | ផ្នែក ៣_រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 51.886,3 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 55,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 51.831,3 |
| | ផ្នែក ៤_ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 630,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 630,0 |
| | ០៦. ក្រសួងការពារជាតិ | 798,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 125,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 673,0 |
| | ០៧. ក្រសួងមហាផ្ទៃ | 91.576,0 |
| | ផ្នែក ១- សន្តិសុខសាធារណៈ | 84.165,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 121,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 84.044,0 |
| | ផ្នែក ៩- សាលាខេត្ត-ក្រុង | 7.411,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 1.894,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 5.517,0 |
| | ០៩. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 49.740,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 1.025,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 48.715,0 |
| | ១០. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 4.997.074,0 |
| | ១.១ ទីចាត់ការគយ និង រដ្ឋាករ | 2.044.818,0 |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 1.181.976,0 |
| 71 | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 858.024,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 4.818,0 |

# តារាងបែងចែកចំណូលចរន្ត និង ចំណូលមូលធន សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨

ឯកតា:លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | ១.២ នាយកដ្ឋានពន្ធដារ | 1.101.500,0 |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 1.100.000,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 1.500,0 |
| | ១.៣ ទីស្តីការក្រសួង | 1.850.544,0 |
| | -ចំណូលចរន្ត | 129.144,0 |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 76.044,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 100,0 |
| 76 | ផលហិរញ្ញវត្ថុ | 13.000,0 |
| 77 | ផលផ្សេងៗ និង ផលពិសេស | 40.000,0 |
| | -ចំណូលមូលធន | 1.721.400,0 |
| 27 | អចលកម្មហិរញ្ញវត្ថុ | 100.000,0 |
| 13 | ឧបត្ថម្ភកធន | 883.250,0 |
| 16 | ការខ្ចី និង ចំណុលប្រហាក់ប្រហែល | 738.150,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 212,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 87,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 125,0 |
| | ១១. ក្រសួងព័ត៌មាន | 1.407,1 |
| | ផ្នែក ១-ក្រសួង | 1.308,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 1.308,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 99,1 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 42,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 57,1 |
| | ១២. ក្រសួងសុខាភិបាល | 1.655,0 |
| | ផ្នែក ១-ក្រសួង | 1.435,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 1.435,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 220,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 220,0 |

# តារាងបែងចែកចំណូលចរន្ត និង ចំណូលមូលធន
# សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨

ឯកតា:លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | ១៣. ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល | 27.509,4 |
| | ផ្នែក ១-ក្រសួង | 24.690,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 1.300,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 6.107,0 |
| 77 | ផលផ្សេងៗ និង ផលពិសេស | 17.283,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 2.819,4 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 1.226,9 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 1.592,5 |
| | ១៥. ក្រសួងពាណិជ្ជកម្ម | 114.362,5 |
| | ផ្នែក ១-ក្រសួង | 114.139,5 |
| 71 | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 90.000,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 524,8 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 23.614,7 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 223,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 19,6 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 203,4 |
| | ១៦. ក្រសួងអប់រំ យុវជន និងកីឡា | 967,0 |
| | ផ្នែក ១-អប់រំ | 717,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 214,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 503,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 250,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 250,0 |
| | ១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 25.222,7 |
| | ផ្នែក ១-ក្រសួង | 24.532,2 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 22.625,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 1.457,2 |
| 74 | ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម | 450,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 690,5 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 2,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 688,5 |

# តារាងបែងចែកចំណូលចរន្ត និង ចំណូលមូលធន សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨

ឯកតា:លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | ១៨. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 2.217,5 |
| | ផ្នែក ១-ក្រសួង | 2.217,5 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 2.217,5 |
| | ១៩. ក្រសួងបរិស្ថាន | 542,0 |
| | ផ្នែក ១-ក្រសួង | 510,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 330,0 |
| 74 | ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម | 180,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 32,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 32,0 |
| | ២២. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 60.645,5 |
| | ផ្នែក ១-ក្រសួង | 59.528,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 59.528,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 1.117,5 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 1.117,5 |
| | ២៥. ក្រសួងសាធារណការ និងដឹកជញ្ជូន | 11.042,4 |
| | ផ្នែក ១-ក្រសួង | 10.921,6 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 8.750,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 2.071,6 |
| 74 | ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម | 100,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 120,8 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 5,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 115,8 |
| | ២៦. ក្រសួងយុត្តិធម៌ | 463,0 |
| | ផ្នែក ១-យុត្តិធម៌ | 75,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 75,0 |
| | ផ្នែក ២-តុលាការកំពូល | 130,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 130,0 |
| | ផ្នែក ៣-សាលាឧទ្ធរណ៍ | 90,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 90,0 |

# តារាងបែងចែកចំណូលចរន្ត និង ចំណូលមូលធន
# សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨

ឯកតា: លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 168,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 168,0 |
| | ២៧. ក្រសួងទេសចរណ៍ | 4.188,3 |
| | ផ្នែក ១-ក្រសួង | 4.109,2 |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 776,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 916,2 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 2.417,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 79,1 |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 26,4 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 6,5 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 46,2 |
| | ២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 3.298,0 |
| | ផ្នែក ១-ក្រសួង | 542,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 542,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 2.756,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 2.756,0 |
| | ៣២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 2.092,0 |
| | ផ្នែក ១-ក្រសួង | 1.900,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 1.880,0 |
| 74 | ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម | 20,0 |
| | ផ្នែក ៩-មន្ទីរជំនាញខេត្ត-ក្រុង | 192,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា | 192,0 |
| | ធនាគារជាតិនៃកម្ពុជា | 35.000,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 35.000,0 |
| | **សរុបចំណូលចរន្ត** | 3.886.916,7 |
| | **រដ្ឋបាលកណ្តាល** | 3.870.526,3 |
| | **មន្ទីរជំនាញខេត្ត-ក្រុង** | 16.390,4 |
| | **សរុបចំណូលមូលធន** | 1.721.400,0 |
| | **សរុបចំណូលថវិកាទូទៅរបស់រដ្ឋ** | 5.608.316,7 |